# ការរៀបចំ និងការកៀរពង្រាបដី បញ្ជាដោយប្រព័ន្ធឡាស៊ែរ



ដោយៈ អគ្គនាយកដ្ឋានកសិកម្ម

## ១. ការគ្រប់គ្រងទឹកក្នុងស្រែ

ស្រូវមិនមែនជារុក្ខជាតិទឹកទេតែវាធន់នឹងទឹក ហើយវាត្រូវការទឹកតិចតួចដើម្បីដុះលូតលាស់ និងត្រូវការទឹកច្រើនចាប់ពីដំណាក់កាលកំណកំណើតក្អួរហូតដល់កកើតជាគ្រាប់។ ការធ្វើឱ្យមានទឹកដក់ជាប្រចាំនៅក្នុងស្រែគឺដើម្បីកាត់បន្ថយការដុះលូតលាស់របស់ស្មៅចង្រៃ។

កត្តាដែលទាក់ទងដល់ការប្រើប្រាស់ និងការបាត់បង់ទឹកក្នុងស្រែ រួមមាន ៖

- ការភាយជាចំហាយទឹកពីផ្ទៃដី ពីផ្ទៃទឹក និងពីស្លឹកដំណាំដោយការដកដង្ហើមរបស់វា
- ការជ្រាបចូលទៅក្នុងដី
- ការបង្ហូរ ឬការហូរចេញពីស្រែ
- រយៈពេលដាំដុះរបស់ដំណាំ។

## ២. ការរៀបចំដី និងភាពរាបស្មើរបស់ដីស្រែ

ការរៀបចំដី ឬការភ្ជួររាស់ដីធ្វើឡើងជាសំខាន់ដើម្បីឱ្យដីមានសភាព ឬលក្ខណៈល្អប្រសើរបំផុតសម្រាប់ការដុះលូតលាស់នៃគ្រាប់ពូជ និងដំណាំ។ យើងគួរភ្ជួររាស់ដីក្នុងជម្រៅមួយដែលធ្វើឱ្យដំណាំអាចចាក់ឫសបានគ្រប់គ្រាន់ ដើម្បីទ្រទ្រង់ដើម និងស្រូបយកសំណើមព្រមទាំងជីជាតិបានស្មើគ្នា។

### ក. គុណសម្បត្តិនៃការរៀបចំដី ដើម្បី ៖

- កំចាត់ស្មៅចង្រៃ កំចាត់សំបុក និងពងសត្វល្អិតចង្រៃ
- បំបែកដុំដី ឬធ្វើឱ្យដីម៉ដ្ឋ
- បង្កើនលទ្ធភាពរបស់ដីក្នុងការរក្សាទុកសំណើម និងប្របល់ និងបង្កប់ជីជាតិបានស្មើល្អ។

### ខ. ភាពរាបស្មើរបស់ដី

ដីស្រែពុំរាបស្មើ ធ្វើឱ្យ ៖

- ត្រូវការទឹកច្រើនសម្រាប់ការភ្ជួររាស់ (ដើម្បីឱ្យសើម ឬលិចសព្វទឹកន្លែង)
- ពិបាកភ្ជួររាស់
- មានបញ្ហាស្មៅចង្រៃលូតលាស់ច្រើន លំបាកគ្រប់គ្រងទឹក និងជី
- ដើមស្រូវមានកម្ពស់មិនស្មើគ្នា ស្រូវទុំមិនដំណាលគ្នា និងមានទំហំគ្រាប់មិនប៉ុនគ្នា។



ដីស្រែមិនស្មើ ធ្វើឱ្យពិបាកភ្ជួររាស់



ស្រូវដុះ និងលូតលាស់មិនស្មើគ្នា



ទឹកក្នុងស្រែមិនសព្វគ្រប់ទីកន្លែង

ជាមធ្យម នៅប្រទេសកម្ពុជា ដីស្រែតែមួយមានកម្ពស់ទាបខ្ពស់ខុសគ្នាប្រមាណជា ០.១៥ម៉ែត្រ (១តឹកកន្លះ)។ នៅក្នុងស្រែខ្លះ ដីអាចខ្ពស់ទាបជាងគ្នារហូតដល់ ០.៣ម៉ែត្រ (៣តឹក) ដែលធ្វើឱ្យមានតម្រូវការទឹកបន្ថែមច្រើនដោយឥតប្រយោជន៍ប្រមាណជា ០.១ម៉ែត្រ (១តឹក)ឬស្មើនឹង ១០% នៃតម្រូវការទឹកសរុបដើម្បីពន្លិចដីឱ្យសព្វគ្រប់ទីកន្លែង។

ការស្រាវជ្រាវបានរកឃើញថា ការរៀបចំពង្រាបដីឱ្យបានស្មើ អាចដោះស្រាយបាននូវបញ្ហានានាដូចខាងលើ ហើយវាក៏ធ្វើឱ្យងាយស្រួលដូចជាៈអាចប្តូរពីការដាំដុះដោយដកស្ទូងទៅជាការព្រោះឬដាំគ្រាប់វិញ ព្រោះការព្រោះឬដាំគ្រាប់អាចកាត់បន្ថយកម្លាំងពលកម្មប្រមាណពី ៣០នាក់ក្នុងមួយថ្ងៃមកត្រឹម ១ ឬ២នាក់ក្នុងមួយថ្ងៃវិញសម្រាប់ស្រែ ១ហិកតា ហើយស្រូវអាចនឹងត្រូវការ រយៈពេលដុះលូតលាស់ តិចជាងមុនប្រមាណជា ៥ ទៅ ១០ថ្ងៃ

- ស្រូវកើនទិន្នផលប្រមាណជា ២០%
- ចាប់ពីឆ្នាំ១៩៩៦ ដល់ ឆ្នាំ១៩៩៩ កម្មវិធីវិស្វកម្មកសិកម្មនៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា បានរកឃើញថា ស្រែដែលបានពង្រាបដីស្មើទទួលបានទិន្នផលជាមធ្យម ២.៧តោនក្នុងមួយហិកតា គឺខ្ពស់ជាង ស្រែដែលមិនបានពង្រាបឱ្យស្មើប្រមាណជា ០.៥តោនក្នុងមួយហិកតា។

## ៣. ការកៀរពង្រាបដីបញ្ញាដោយប្រព័ន្ធឡាហ្សែរ

យើងអាចកៀរពង្រាបដីស្រែដែលភ្ជួររួចដោយប្រើប្រាស់គោក្របី គោយន្ត ឬត្រាក់ទ័រដោយបំពាក់ជាមួយរនាស់ ធ្មេញធម្មតា ឬជាមួយក្លៀរ ឬប៉ែល។ ដើម្បីកៀរដីឱ្យមានប្រសិទ្ធភាព ក្តារកៀរដី ឬរនាស់ត្រូវមានទម្ងន់យ៉ាងតិច ៤០ គីឡូក្រាមសម្រាប់ប្រវែងរនាស់ ឬក្លៀរ ១ម៉ែត្រ។

បច្ចុប្បន្ន ការកៀរពង្រាបដីបញ្ញាដោយកាំរស្មីឡាហ្សែរ កំពុងត្រូវបានគេនិយមចូលចិត្តប្រើ ហើយមានប្រសិទ្ធភាពក្នុងកិច្ចប្រតិបត្តិជាច្រើនក្នុងវិស័យកសិកម្ម។ វិធីនេះ ធ្វើឱ្យអ្នកប្រតិបត្តិមានភាពងាយស្រួល និងអាចកៀរដីបានយ៉ាងរាបស្មើដែលអាចខ្ពស់ទាបជាងគ្នាតិចជាង ២ សង្ទីម៉ែត្រតែប៉ុណ្ណោះ។ ប្រព័ន្ធបញ្ញានេះ ដែលរួមមានទាំងប៉ែល ឬក្លៀផងមានតម្លៃប្រមាណជា ១០.០០០ ដុល្លារ (មួយម៉ឺនដុល្លាអាមេរិច។





បរិក្ខារកៀរពង្រាបដីបញ្ញាដោយប្រព័ន្ធឡាហ្សែរ

### ៣.១ ការវាស់ស្ទង់ស្ថានភាពដី

មុននឹងកៀរពង្រាបស្រែគោក ចាំបាច់ត្រូវវាស់ស្ទង់នូវសភាពខ្ពស់ទាបរបស់ផ្ទៃដីក្នុងស្រែជាមុនសិន។ ការវាស់ស្ទង់នេះធ្វើឱ្យយើងដឹងពីទីកន្លែង ឬចំណុចនានាដែលត្រូវកៀរយកដីចេញ ឬត្រូវកៀរយកដីចូលទៅតាមស្ថានភាពដីស្រែហើយធ្វើឱ្យយើង អាចប្រមាណបាននូវតម្លៃ ឬពេលវេលា ដែលត្រូវចំណាយ។

### ៣.២ ឧបករណ៍វាស់ស្ទង់ដីប្រភេទអុបទិក

មុននឹងធ្វើការវាស់ស្ទង់ដោយឧបករណ៍នេះ យើងត្រូវដៅ ឬកំណត់ចំណុចដែលត្រូវវាស់ស្ទង់ទុកជាមុនសិន ដែលចំណុចទាំងនោះគួររាយគ្នាជាក្រឡាចត្រង្គ ហើយឃ្លាតពីគ្នាប្រមាណ១០ ម៉ែត្រ។ បន្ទាប់មកដំឡើងឧបករណ៍កែវស្ទង់ នៅលើជើងទម្ររបស់វា ដោយកែសម្រួលធ្វើឲ្យវាស្ថិតក្នុងប្លង់ដេកដែលនៅពេលនោះពពុះទឹកខិតមកចំចំណុចកណ្តាលនៃកែវស្ទង់ (កែវស្ទង់នីវ៉ូ)។

យើងត្រូវការតែមនុស្ស ២នាក់សម្រាប់ធ្វើកិច្ចការនេះ គឺម្នាក់ជាអ្នកពិនិត្យកម្រិតកម្ពស់ក្នុងកែវស្ទង់ ហើយកត់ត្រាលេខនោះ និងម្នាក់ទៀតជាអ្នកកាន់ម៉ែត្របញ្ឈរ (ក្តារលេខ) ទៅតាមចំណុចដែលបានកំណត់។



*ការពិនិត្យមើលកម្រិតខ្ពស់ទាប*




*គំនូសតាងការវាស់ស្ទង់ដោយឧបករណ៍អុបទិក*

កត់ត្រានូវតួលេខ ដែលពិនិត្យឃើញពីក្នុងកែវស្ទង់ ឧទាហរណ៍ ត្រង់ A = 1 ម៉ែត្រ ត្រង់ B = 1.5 ម៉ែត្រ និង ត្រង់ C = 1.2 ម៉ែត្រ។

គណនាកម្រិតមធ្យម

$$\frac{1+15+12}{3} = 1.23$$ ម៉ែត្រ។

គណនារកកម្រាស់ដីដែលត្រូវកៀរចេញ ឬកៀរចូល

- សម្រាប់ចំណុច A យើងយក 1.00-1.23= - 0.23ម៉ មានន័យថាត្រូវកៀរយកដីចេញពីចំណុច A កម្រាស់ 0.23ម៉
- សម្រាប់ចំណុច B យើងយក 1.50-1.23=+0.27ម៉ មានន័យថាត្រូវកៀរយកដីទៅដាក់បន្ថែមត្រង់ B កម្រាស់ 0.27ម៉
- សម្រាប់ចំណុច C យើងយក 1.20-1.23 = - 0.03ម៉ មានន័យថាត្រូវកៀរយកដីចេញពីចំណុច C កម្រាស់ 0.03ម៉។

### ៣.៣ ការវាស់ស្ទង់ដីដោយប្រព័ន្ធឡាស្សែរ

វាជាមធ្យោបាយវាស់ស្ទង់ដីដ៏មានប្រសិទ្ធភាព ទៀងទាត់ងាយស្រួលប្រើប្រាស់ និងអាចវាស់ស្ទង់បានក្នុងកាំចម្ងាយ ៣០០ម៉ែត្រ។ ប្រព័ន្ធឡាស្សែរសម្រាប់ វាស់ស្ទង់រួមមាន ៖ ប្រដាប់បញ្ចេញកាំរស្មីឡាស្សែរ ជើងជ្រែងទ្រម៉ែត្របន្ទាត់ និងប្រដាប់ទទួលកាំរស្មីតូចមួយ។



### ៣.៤ ប្រព័ន្ធបញ្ជាឡាស្សែរ

កាំរស្មីឡាស្សែរដែលចេញពីប្រដាប់បញ្ចេញ ត្រូវបានទទួលដោយប្រដាប់ទទួល ដែលដាក់ជំឡើងនៅលើប៉ែល ឬធុងកៀរដី។ ប្រអប់បញ្ជា ដែលដាក់នៅលើត្រាក់ទ័រ បំពេញមុខងារទៅតាមសញ្ញា ដែលផ្តល់ឱ្យដោយ ប្រដាប់ទទួលនោះ ដោយបញ្ជាឱ្យបើក ឬបិទវ៉ាល់បញ្ហាអ៊ីដ្រូលិច ធ្វើឱ្យប៉ែល ឬធុងកៀរដីលើកឡើង ឬបន្ទាបចុះដោយស្វ័យប្រវត្តិ។




### ៣.៥ ការកៀរពង្រាបដីដោយប្រព័ន្ធឡាស្សែរ

ការកៀរពង្រាបស្រែគោកច្រើនត្រូវបានគេអនុវត្តដោយប្រើប្រាស់ ត្រាក់ទ័របំពាក់ជាមួយធុងកៀរពីក្រោយ។ ត្រូវភ្ជួររាស់ដីឱ្យសព្វ ហើយធ្វើកុំឱ្យមានស្មៅ ឬសំណល់ដំណាំផ្សេងៗ។ ដីដែលនៅសើមខ្លាំង និងមានស្មៅ ឬសំណល់ដំណាំច្រើននឹងធ្វើឱ្យធុងកៀរដីកៀរមិនបានល្អ។ ជាមធ្យម គេត្រូវការពេលពី ៣ ទៅ ៤ម៉ោង ដើម្បីកៀរដីស្រែ ១ហិកតា ចំពោះផ្ទៃដីដែលមានសភាពទាបខ្ពស់ជាងគ្នាប្រមាណជា ១០សង្ទីម៉ែត្រ។








## ៤. គុណសម្បត្តិនៃការប្រើប្រាស់ប្រព័ន្ធឡាហ្សែរ

ការប្រើប្រាស់ប្រព័ន្ធបញ្ជាឡាហ្សែរ ធ្វើឱ្យការកៀរពង្រាបដីអាច ចំណាយពេលតិចជាងវិធីផ្សេងៗទៀត ប៉ុន្តែវាអាស្រ័យលើភាពស្ទាត់ជំនាញ ឬ ភាពប៉ិនប្រសប់នៃអ្នកប្រតិបត្តិ បរិមាណដីត្រូវកៀរ ប្រភេទដី និងសណ្ឋាន ភាពដីស្រែ។ ប្រព័ន្ធនេះ អាចជួយឱ្យការកៀរដីបានស្មើល្អ ដោយមានភាព ខ្ពស់ទាបជាងគ្នាតិចជាង ២សង្ទីម៉ែត្រ។



# ពាណិជ្ជកម្មសណ្តែកបាយនៅប្រទេសចិន



ដោយ: នាយកដ្ឋានសាកវប្បកម្មនិងដំណាំរួមផ្សំ នៃអគ្គនាយកដ្ឋានកសិកម្ម



ជាទូទៅ រដូវកាលដាំដុះអំបូរសណ្តែកបាយនៅតំបន់ភាគពាយ័ព្យនៃខេត្តជីលិនប្រទេសចិនចាប់ផ្តើមពីពាក់កណ្តាលខែឧសភា រហូតដល់ពាក់កណ្តាលខែមិថុនា។ ពូជដែលកសិករចិននិយមចូលចិត្តដាំមាន៣ប្រភេទគឺ (១)ពូជស្រាលអាយុកាលប្រមាណ៨០ថ្ងៃជាពូជពុំធន់ទ្រាំជំងឺ (២)ពូជកណ្តាលអាយុកាលប្រមាណ១០០ថ្ងៃ ជាពូជសមស្របក្នុងតំបន់ និង (៣)ពូជធ្ងន់អាយុកាលប្រមាណ១២០ថ្ងៃ ជាពូជដែលមិនអាចទុំបានល្អមុនរដូវធ្លាក់ទឹកកកមកដល់។ សណ្តែកបាយត្រូវបានដាំជាដំណាំឯកវប្បកម្ម ឬដាំចំរុះជាមួយដំណាំពោត ឪឡឹក និងកប្បាស។





ពពួកអំបូរពូជសណ្តែកបាយ Vigna radiate ពិសេសពូជ Radiata ដែលផលិតនៅក្នុងតំបន់ភាគពាយ័ព្យនៃខេត្ត ជីលិន មានភាពល្បីល្បាញ បំផុតដោយសារផ្លែសណ្តែកបាយដាក់គ្រាប់ពេញ ទំហំគ្រាប់ធំ មានពណ៌បៃតងភ្លឺរលោង ភាគរយដំណុះខ្ពស់ និងមានរសជាតិល្អប្រសើរ។

ក្នុងចំណោមសណ្តែកបាយ ៧០ពាន់តោន ដែលបាននាំចេញពីក្រុងបៃចេងជារៀងរាល់ឆ្នាំ ជាង៥០ពាន់តោនជាសណ្តែកបាយដែលមានគុណភាពដំណុះល្អ និងមានតម្លៃខ្ពស់។



ពូជសណ្ដែកបាយទាំងនេះ បានមកពីស្រឡាយពូជដែលបានរក្សាទុកនៅមជ្ឈមណ្ឌលដំណាំបន្លែពិភពលោក នាឆ្នាំ ១៩៨៣ ដែលបានកែលម្អរួច ហើយបានឆ្លងកាត់ការវាយតម្លៃជាបន្តបន្ទាប់ដោយមជ្ឈមណ្ឌលបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មនៃប្រទេសចិន។ រហូតដល់ឆ្នាំ១៩៩៣ស្រឡាយពូជរបស់មជ្ឈមណ្ឌលដំណាំបន្លែពិភពលោកឈ្មោះ VC1973A ត្រូវបានរំដោះដោយមានឈ្មោះថា ZhongLu#1 ដែលជាពូជសណ្ដែកបាយដំបូងបង្អស់ដាក់ឱ្យធ្វើការដាំដុះទូទាំងប្រទេសចិនជំនួសពូជចាស់ពីដូនតាដែលមានតាំងពីឆ្នាំ១៩៤៩។ មជ្ឈមណ្ឌលដំណាំបន្លែពិភពលោក ជាមជ្ឈមណ្ឌលដំណាំបន្លែ អន្តរជាតិ ដែលមានធនាគារពូជដ៏ធំ ដោយបានប្រមូលពូជបន្លែជាច្រើនពីគ្រប់ទិសទីមករក្សាទុកសម្រាប់ប្រើប្រាស់ទាំង បច្ចុប្បន្ន និងទៅអនាគត ដែលក្នុងនោះធនាគាបានប្រមូលនិងរក្សាទុកពូជសណ្ដែក Vigna ១០.០០០ accessions-បញ្ជីក ដែលក្នុងនោះមានសណ្ដែកបាយ ៦.៣៧៩ accessions-បញ្ជីក។

ជំងឺសំខាន់ៗដលែបំផ្លាញសណ្តែកហាយរួមមានជំងឺស្លឹកលឿង(Yellow Mosaic) ជំងឺអុចស្លឹកសែកូសស្ពរ៉ា និងជំងឺម្សៅ powdery mildew។

ក្រោយការប្រមូលផលនិងរក្សាទុកដាក់ក្នុងឃ្លាំងរយៈពេលពី២-៣ខែ ទើបលេចឡើងនូវវត្តមានលត្វល្អិតពពួក ខ្មូត bruchids ក្នុងករណីពុំមានវិធានការការពារក្នុងឃ្លាំង។ ចំពោះពូជរំដោះចេញថ្មីៗដាក់ឱ្យប្រើប្រាស់និងធ្វើការដាំដុះ ភាគច្រើនផ្ដល់នូវទិន្នផលខ្ពស់ សំបកគ្រាប់ពណ៌លឿង មានជាតិដែកខ្ពស់ និងធន់ទ្រាំជម្ងឺអុចស្លឹក បាននឹងកំពុងទទួលប្រជា ប្រិយភាពខ្ពស់ក្នុងចំណោមកសិករ។ បច្ចុប្បន្នមជ្ឈមណ្ឌលបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មនៃប្រទេសចិនកំពុងយកចិត្តទុក ដាក់ធ្វើការសិក្សាស្រាវជ្រាវ លើបណ្ដាពូជសណ្ដែកបាយ ទៅលើភាពធន់ទ្រាំចំពោះជាតិប្រៃ ដែលនេះជាក្ដីរំពឹងទុកសម្រាប់ ផលិតកម្មនៅចម្ការ។

អ្នកបរិភោគភាគច្រើន ចូលចិត្តសណ្ដែកបណ្ដុះដែលមានសម្បុរសភ្លឺនិងស្រួយ មានឬសខ្លីនិងស្លឹកតូចៗ គ្មានភ្ជាប់ដោយបាក់តេរី ឬសារធាតុគីមី។ តម្រូវការទីផ្សារសណ្ដែកបណ្ដុះទាំងនៅក្នុងស្រុកនិងសម្រាប់នាំចេញគឺស្របទៅតាម ស្តង់ដាដែលទំហំដើមមានពី៣,២-៣,៨ម.ម. អាយុកាលបណ្ដុះរយៈពេល៧ថ្ងៃ និងតម្លៃសមរម្យ ។

បច្ចុប្បន្នប្រទេសចិនមានក្រុមហ៊ុនសណ្ដែកបណ្ដុះខ្នាតធំចំនួន១៨ ដែលមានសមត្ថភាពផលិតពី៦០ទៅ២០០តោនជារៀងរាល់ថ្ងៃ។

សណ្ដែកបាយគឺជាអាហារចម្បងរបស់ជនជាតិចិនតាំងពីយូរលង់ណាស់មកហើយ។ ក្រុងសាវយួនដែលស្ថិតក្នុងខេត្ត សាងដុងគឺជាកន្លែងផលិតសរសៃគុយទាវ (vermicelli) ពីសណ្ដែកបាយតាំងពី៣០០ឆ្នាំមុន ហើយសព្វថ្ងៃមានផលិតករផលិតសរសៃគុយទាវបែបនេះជាង១៦០កន្លែង។ បន្ទះគុយទាវផលិតពីម្សៅសណ្ដែកគឺជាអាហារប្រពៃណីដ៏មានប្រជា ប្រិយភាពនិងពេញនិយមចូលចិតបំផុតក្នុងប្រទេសចិនភាគខាងកើត។ បន្ទះគុយទាវសរសៃធំបែបនេះ ត្រូវបានផលិតឡើង ដោយដៃឬដោយម៉ាស៊ីនពាក់កណ្ដាលស្វ័យប្រវត្តិ។ សរសៃគុយទាវដែលផលិតដោយដៃមានសណ្ឋានស្តើង ពណ៌ស និង ភ្លឺថ្លាជាងសរសៃគុយទាវដែលធ្វើឡើងដោយម៉ាស៊ីន ហើយកាន់តែមានប្រជាប្រិយភាពក្នុងចំណោមអ្នកបរិភោគទៀត ផង។ ចំណែកឯនំនិងភេសជ្ជៈដែលធ្វើពីសណ្ដែកបាយគឺជារបស់ពិសេសនារដូវក្ដៅ។


















អនុផលនៃផលិតកម្មម្សៅសណ្ដែកត្រូវបានប្រើប្រាស់សម្រាប់ផលិតប្រូតេអ៊ីន និងជាវត្ថុធាតុដើមធ្វើជាផលិតផលចំណីអាហារច្រើនប្រភេទ ជួយទ្រទ្រង់រាង្គកាយ និងផ្ដល់ជាអាហារូបត្ថម្ភយ៉ាងគាប់ប្រសើរ។ ក្រុមហ៊ុន Taonan City Jidou Trading ក្នុងក្រុងតាវណាន ខេត្តជីលីនមានសមត្ថភាពកែច្នៃសណ្ដែកបាយបាន ១០០តោនក្នុងមួយថ្ងៃ។ ក្រុមហ៊ុន នេះពឹងផ្អែកលើវត្ថុធាតុដើមដែលជាសណ្ដែកផលិតក្នុងស្រុក ដើម្បីផលិតចេញជាផលិតផលសម្រេចសម្រាប់ទីផ្សារក្នុង ស្រុកនិងអន្តរជាតិ ជាពិសេសទីផ្សារតំបន់អាស៊ី-អគ្នេយ៍។ ក្រៅពីនោះក៏នៅមានក្រុមហ៊ុនជាច្រើនទៀតបានដំណើរការ អាជីវកម្មពាណិជ្ជកម្មរបស់ខ្លួនលើការផលិតភេសជ្ជៈច្រើនបែបដោយប្រើវត្ថុធាតុដើមពីសណ្ដែកដូចគ្នា។

### ឯកសារពិគ្រោះ

- ព្រឹត្តិបត្រព័ត៌មានមជ្ឈមណ្ឌលបន្លែពិភពលោក-AVRDC ចេញផ្សាយ ខែសីហា ឆ្នាំ២០១២

# ប៉មឃ្លាំមើលព្រៃលិចទឹក

រៀបរៀងដោយៈ លោក ហេង ពិសិដ្ឋ នាយខណ្ឌរដ្ឋបាលជលផលបាត់ដំបង

## ១. សេចក្តីផ្តើម

ព្រៃលិចទឹកមានសារៈសំខាន់បំផុតដល់អាយុជីវិតនៃវិស័យជលផល។ បម្រែបម្រួលអាកាសធាតុជាបច្ច័យអវិជ្ជមាន នាំក្តីកង្វល់ដល់ភាពងាយទទួលរងគ្រោះដោយសារភ្លើងឆេះ។ បាតុភូតភ្លើងឆេះព្រៃលិចទឹក កាលពីខែ មេសា ឆ្នាំ ២០០៩ នៅខេត្តបាត់ដំបង បានក្លាយជាបទពិសោធន៍អាក្រក់និងបានជំរុញឲ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំង ក្នុងការរិះរកវិធានការនិងយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងភ្លើងឆេះព្រៃលិចទឹក។ ដើម្បីជាមធ្យោបាយផ្តល់ព័ត៌មានជាក់លាក់និងចុះជួយអន្តរាគមន៍ពន្លត់ភ្លើងឆេះទាន់ពេលវេលានៅខណ្ឌរដ្ឋបាលជលផលបាត់ដំបង មានរៀបចំប៉មឃ្លាំមើលព្រៃលិចទឹក បានចំនួន ១៤ កន្លែង រាយប៉ាយនៅក្នុងតំបន់ព្រៃលិចទឹក ដែលជាការឧបត្ថម្ភពីអាជីវករឡូត៍នៃសាទ អង្គការអភិវឌ្ឍន៍ស្ត្រីនិងក្រុមហ៊ុន CamGSM Co.,Ltd. ( Mobitel ) ។

គោលបំណងនៃការរៀបចំចងក្រងអត្ថបទនេះឡើង គឺដើម្បីបង្ហាញពីបទពិសោធន៍ សារៈប្រយោជន៍ និងភាពចាំបាច់ឲ្យមានការចូលរួមកាន់តែច្រើនក្នុងការកសាងប៉ម នៅតាមតំបន់ព្រៃលិចទឹក និងព្រៃកោងកាង នៅទូទាំងតំបន់ព្រៃលិចទឹក នៃព្រះរាជាណាចក្រកម្ពុជា។

## ២. និយមន័យ និងប្រភេទប៉ម ?

តាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ចេញផ្សាយដោយពុទ្ធសាសនបណ្ឌិតបានឲ្យនិយមន័យ ប៉ម ថា" ជាគ្រឹហាខ្ពស់ស្រឡះ មានសណ្ឋានមូល ឬកាច់ជ្រុង មានជញ្ជាំងចោះជាប្រហោងជុំវិញ ធ្វើទុកនៅត្រង់មុមកំពែងបន្ទាយ ឬនៅទីណាមួយ សម្រាប់ពួនយាមល្បាតឃ្លាំ ឬលាក់ខ្លួនពួនចាំបាញ់តយុទ្ធនឹង ខ្មាំងសត្រូវ" ។ដោយឡែកសម្រាប់ ប៉ម ដែលនឹងពិពណ៌នាក្នុងអត្ថបទនេះ សំដៅដល់បង្កើតទីតាំងមួយ សម្រាប់ការគ្រប់គ្រង ទប់ស្កាត់រាល់អំពើប៉ះពាល់លើព្រៃលិចទឹក ជាពិសេសភ្លើងឆេះព្រៃលិចទឹក។

ប្រហែលជាលោកអ្នកបានឃើញ បានឮ បានដឹង ហើយថា អ្នកដើរព្រៃ ឬ អ្នកវង្វេងផ្លូវក្នុងព្រៃ តែងតែរកដើមឈើខ្ពស់ៗ រួចឡើងទៅផ្នែកខាងចុង ដើម្បីសំឡឹងរកគោលដៅ ឬ ច្រកចេញ ឬស្ថានភាពព្រៃនៅជុំវិញ។ ផ្តើមពីករណីនេះ ការរៀបចំប៉មឃ្លាំមើលព្រៃលិចទឹក តាមដើមឈើខ្ពស់ៗផ្តល់នូវការចាំបាច់ផងដែរ ។ សម្រាប់ភាពគង់វង្សយូរអង្វែង និងបម្រើគោលបំណងច្រើនយ៉ាងគេត្រូវរៀបចំសំណង់រឹងមាំទៅតាមស្ថានភាពជាក់ស្តែង នៃតំបន់ព្រៃលិចទឹក។ ប៉ុន្តែ ការណ៍នេះ វាត្រូវការទុន និងពេលវេលា។ ទោះជាធំ ឬតូច ការគិតគូរសម្រាប់ធ្វើប៉ម ត្រូវតែផុតពីចុងឈើ ហើយអាចទ្រទម្ងន់មនុស្សយ៉ាងតិច ចំនួន ៣នាក់ ដើម្បីជាសហការី ក្នុងការពិគ្រោះយោបល់។ ខាងក្រោមជាប្រភេទ ប៉ម ដែលគួររៀបចំក្នុងនាទីព្រៃលិចទឹកៈ

១- ប៉មជារានលើចុងឈើៈ ប្រភេទនេះ គេត្រូវស្វែងរកដើមឈើធំ ខ្ពស់ រួចចាប់ផ្តើមសង់រានឲ្យត្រដែតខ្ពស់ផុតពីចុងឈើ។ ប្រភេទនេះ ប្រឈមនឹងការខូចខាតដោយភ្លើងឆេះ ប៉ុន្តែងាយសាងសង់ និងចំណាយទុនតិច។



ប៉មឃ្លាំមើលព្រៃលិចទឹក នៅលើចុងឈើដែលចំណាយថវិកាតិច

២- ប៉មធ្វើពីឈើ ឬជាដែក ឬបេតុង៖ ប្រភេទនេះ គេអាចសង់នៅគ្រប់ទីកន្លែងផ្ទាល់នឹងដី ហើយត្រូវមានរានខ្ពស់ផុតពីចុងឈើ ដោយមានកាំជណ្ដើរត្រឹមត្រូវ ។ ប៉មដែកឬ ប៉មបេតុងមានភាពធន់ទ្រាំនឹងភ្លើងឆេះ ប៉ុន្តែត្រូវចំណាយច្រើនលើការសាងសង់។





ប៉មឃ្លាំមើលព្រៃលិចទឹកធ្វើអំពីបេតុង និងដែក

## ៣. ទីតាំង ការកសាង និងសម្ភារបំពាក់

ទោះបីជា ប៉មជារានលើចុងឈើ ឬប៉មជាឈើ ឬប៉មជាដែក ឬប៉មជាបេតុង ការជ្រើសរើសទីតាំងកសាងជាប៉ម មានការចាំបាច់ ជាពិសេសផ្ដោតលើប្រសិទ្ធភាពក្នុងការប្រើប្រាស់។ ដូច្នេះការកសាងប៉ម ត្រូវពិចារណាលើ៖

១-ច្រកចេញ ចូល៖ ក្នុងនាទីព្រៃលិចទឹក មានច្រកចេញ ចូលជាច្រើន ដែលប្រជាពលរដ្ឋ ចូលទៅដកហូតផលពីក្នុងព្រៃលិចទឹក ។ ការកំណត់យកទីតាំងនេះ អាចបង្កើនការចាប់អារម្មណ៍ពីអ្នកទាំងឡាយ ចំពោះព្រៃលិចទឹក ហើយក៏មានការងាយស្រួល ក្នុងការផ្ដល់ឱកាសសម្រាប់អ្នកទាំងពួងដែលបានឆ្លងកាត់ ហើយជួបប្រទះហេតុការណ៍ រាយការណ៍ជូនសមត្ថកិច្ច។

២-ក្បែរប្រភពទឹក៖ ងាយស្រួល ក្នុងការបូមទឹកអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក។

៣-ព្រំប្រទល់រវាងនាទីព្រៃលិចទឹកនិងដីដាំដុះដំណាំកសិកម្ម៖ ទីតាំងបែបនេះសម្រាប់ឱ្យម្ចាស់ស្រែ ឬ ចំការបានចូលរួមក្នុងការផ្ដល់ព័ត៌មាន ឬអន្តរាគមន៍ពន្លត់ភ្លើងឆេះ។ ក្រៅពីនេះ ទីតាំងប៉ម នឹងក្លាយជាព្រំកំណត់ ទប់ស្កាត់ការរាន ព្រៃបន្តទៀត។

## ៤- ចម្ងាយពីប៉មមួយ ទៅប៉មមួយ

ដើម្បីវិសាលភាពគ្រប់គ្រងតំបន់ព្រៃលិចទឹកទាំងមូល គេត្រូវសាងសង់ប៉ម ក្នុងកម្រិតចង្ងាយពីគ្នា ក្នុងចន្លោះពី ២ ទៅ ៣ គីឡូម៉ែត្រ។

អ្នកប្រចាំការតាមទីតាំងប៉មនីមួយៗ និងលេខទូរស័ព្ទសមត្ថកិច្ច បំពាក់លើអគារប៉ម មានសារសំខាន់ណាស់ សម្រាប់ទំនាក់ទំនងផ្ដល់ព័ត៌មាន និងស្នើសុំកិច្ចអន្តរាគមន៍។ ក្រៅពីនេះ វិទ្យុទាក់ទង ទូរស័ព្ទ កែវយឺត telescop និងឧបករណ៍សម្ភារពន្លត់ភ្លើងឆេះ ត្រូវតែមាននៅតាមប៉មនីមួយៗ។

## ៥. ការប្រើប្រាស់ និងសារប្រយោជន៍

អ្នកប្រចាំការតាមទីតាំងប៉មនីមួយៗ ជាការចាំបាច់បំផុត។ សហគមន៍នេសាទនិងអាជីវកម្មឡូត៍នេសាទ ត្រូវមានតួនាទីសំខាន់ ចាត់តាំងកម្លាំងប្រចាំការ។ ដោយឡែកប្រជាពលរដ្ឋគ្រប់រូប ដែលធ្វើដំណើរឆ្លងកាត់ ឬមានបំណង រាយការណ៍ពីបាតុភាពលើព្រៃលិចទឹក ត្រូវឡើងទៅលើប៉ម ពិនិត្យស្ថានភាព រួចរាយការណ៍មកសមត្ថកិច្ច តាមលេខទូរស័ព្ទភ្ជាប់នឹងប៉ម។ ប៉មឃ្លាំមើលព្រៃលិចទឹក ជាទីសាធារណៈ និងជាទ្រព្យ

សម្បត្តិរបស់រដ្ឋ អាចប្រើប្រាស់បានដោយជនគ្រប់រូប ក្នុងគោលបំណង និរន្តរភាពធនធានព្រៃលិចទឹក។ ជនទាំងឡាយណាដែលធ្វើឲ្យខូចខាតដល់ប៉មឃ្លាំមើលព្រៃលិចទឹក ត្រូវទទួលទោសតាមច្បាប់ស្ដីពីជលផល។

តាមការសិក្សាវិភាគ ប៉មឃ្លាំមើលព្រៃលិចទឹក មានសារៈប្រយោជន៍ដូចខាងក្រោមៈ

ក- ជាតំបន់តាមដានឃ្លាំមើលសកម្មភាពនានាប៉ះពាល់ដល់ព្រៃលិចទឹកនិងសកម្មភាពបទល្មើសជលផលផ្សេងៗទៀត ដើម្បីរាយការណ៍ជូនសមត្ថកិច្ច និងចាត់ការអន្តរាគមន៍ទាន់ពេលវេលា។

ខ-កំណត់បានជាក់លាក់នូវទីតាំងទទួលរងផលប៉ះពាល់ព្រៃលិចទឹក ដូចជាកន្លែងកំពុងទទួលរងភ្លើងឆេះ ព្រៃលិចទឹក និងសកម្មភាពទន្ទ្រានដីព្រៃលិចទឹក។

គ-ជាតំបន់ដែលអាចពញ្ញាក់អារម្មណ៍ដល់ជនគ្រប់រូបឲ្យមានការចូលរួមថែរក្សា ការពារព្រៃលិចទឹក។

## ៦. បទពិសោធន៍ និងយន្តការបន្ថែម

ទោះបីជាមានប៉មឃ្លាំមើលព្រៃលិចទឹក មិនមែនមានន័យថា មិនមានភ្លើងឆេះព្រៃលិចទឹក ឬ មិនមានសកម្មភាពឆ្លៀតឱកាសបំផ្លាញព្រៃលិចទឹកនោះទេ។ យើងត្រូវមានការអប់រំផ្សព្វផ្សាយ អំពីអត្ថន័យរបស់ប៉ម សារប្រយោជន៍របស់ប៉មនិងរបៀបប្រើប្រាស់ប៉ម ដើម្បីឲ្យប៉មត្រូវបានអ្នកផងទាំងពួង ចូលរួមប្រើប្រាស់ជាប្រចាំ។ បើមិនដូច្នេះទេ ប៉មឃ្លាំមើលព្រៃលិចទឹកនឹងគ្រាន់តែជាខ្ទមនៅកណ្ដាលព្រៃតែប៉ុណ្ណោះ។

ដើម្បីឲ្យប៉មទាំងនោះ សម្រេចបានតាមគោលបំណងនៃការគ្រប់គ្រងព្រៃលិចទឹកប្រកបដោយនិរន្តរភាពគួរមានយន្តការបន្ថែមទៀតដូចជាៈ

ក-បណ្ដុះបណ្ដាល ឬអប់រំផ្សព្វផ្សាយ ពីរបៀបអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃងាយៗ ប្រជាពលរដ្ឋនៅក្បែរតំបន់ព្រៃលិចទឹក

ខ-រៀបចំផ្លូវភ្លើង ទប់ស្កាត់ការឆេះរាលដាលព្រៃលិចទឹក ពីតំបន់មួយ ទៅតំបន់មួយ

គ-បញ្ជ្រាបការយល់ដឹងអំពីអត្ថប្រយោជន៍ព្រៃលិចទឹក ដល់ស្រទាប់សិស្ស និស្សិត

ឃ-រៀបចំថ្នាលបណ្ដុះកូនឈើព្រៃលិចទឹក និងចលនាដាំកូនឈើព្រៃលិចទឹក គ្រប់ទីកន្លែង

ង-សិក្សា ជីក និងស្ដារបឹង ព្រែក អូរ ប្រឡាយ ឲ្យមានទឹកគ្រប់គ្រាន់នៅរដូវប្រាំង ដើម្បីប្រយោជន៍ជាផ្លូវភ្លើងផងនិងជាប្រភពទឹកអន្តរាគមន៍ផង៕



